**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ7-01-166 ប្រក

# ប្រកាស
## ស្តីពី
## ប្រាក់តំកល់ធានាលើដើមទុន

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០៣៩៨ / ៨៥ ចុះថ្ងៃទី ១០ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

## សំរេច

**ប្រការ ១.-**

កំណត់ប្រាក់តំកល់ធានាលើដើមទុនដែលត្រូវដាក់ផ្ញើជាអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងមាត្រា១៦នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន១០ភាគរយនៃដើមទុន ។

**ប្រការ ២.-**

ប្រាក់តំកល់ធានាលើដើមទុនដែលមានស្រាប់ គិតមកដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០០ នឹងត្រូវបំពេញអោយដល់ចំនួនយ៉ាងតិចដប់ភាគរយ ( ១០ % ) នៃដើមទុនចុះបញ្ជីរបស់ធនាគារអោយបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ។

ប្រការ ៣.-

ធនាគារដែលត្រូវបានអនុញ្ញាតអោយពន្យារពេលសំរាប់បង្កើនដើមទុនអប្បបរមាដល់កំរិតចំនួន - ហាសិបពាន់លានរៀល ( ៥០,០០០,០០០,០០០៛ ) ក្នុងឆ្នាំ២០០១ នឹងត្រូវបង់ប្រាក់តំកល់ធានាលើដើមទុន តាមសមាមាត្រនៃដើមទុនដែលបានបង់តាមដំណាក់កាលដែលភាគទុនិកបានសន្យា ។

ក្នុងករណី ការបង្កើនដើមទុនត្រូវបានដកយកមកពីប្រាក់ចំណេញរក្សាទុក ( Retained Earning ) ប្រាក់តំកល់ធានាលើដើមទុន ត្រូវបានបង់ព្រមពេលជាមួយនឹងការសំរេចរបស់ភាគទុនិកអោយផ្ទេរប្រាក់ចំណេញមកជាដើមទុន។

ប្រការ ៤.-

ប្រាក់តំកល់ធានាលើដើមទុនអាចអនុវត្តជាប្រាក់រៀល ឬជាប្រាក់ដុល្លារអាមេរិក ។ បន្ទាប់ពីបានបង់ប្រាក់តំកល់ធានាលើដើមទុន ធនាគារសាមីមិនអាចផ្លាស់ប្តូរការជ្រើសរើសនេះបានទេ ។ អត្រាប្តូរប្រាក់ប្រើប្រាស់សំរាប់ការគណនាប្រាក់តំកល់ធានាលើដើមទុននេះ គឺជាអត្រាប្តូរប្រាក់ផ្លូវការនៅថ្ងៃដែលមូលនិធិត្រូវបានចុះឥណទានគណនីតំកល់ធានានៅធនាគារជាតិនៃកម្ពុជា ។

ប្រការ ៥.-

ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀលទទួលបានកំរៃការប្រាក់ មួយភាគពីរនៃអត្រាការប្រាក់បុនហិរញ្ញប្បទានក្នុងរយៈពេល ៦ ខែម្តងជាចរមាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

ប្រាក់តំកល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេស ទទួលបានកំរៃការប្រាក់តាមអត្រា ៣/ ៨ នៃ SIBOR ( Singapore Inter-Bank Offered Rate ) ក្នុងរយៈពេល៦ខែម្តង ។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងទៅធនាគារទាំងអស់ពីអត្រាការប្រាក់ដែលបានអនុវត្តសំរាប់កាលកំណត់ និមួយៗ ។

ប្រការ ៦.-

ប្រាក់តំកល់ធានាលើដើមទុន ត្រូវបានសងត្រលប់ទៅវិញតែក្នុងករណីមានការជំរះបញ្ជីធនាគារ និងស្របតាមលំដាប់អាទិភាពដែលមានចែងនៅមាត្រា៦៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៧.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ១០ ឆ្នាំ២០០១

ទេសាភិបាល

ជា ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ៨ " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី " ដើម្បីជ្រាបជាពតិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី " ដើម្បីចុះផ្សាយក្នុងរាជកិច្ច"